**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់វិទ្យាស្ថាន អេសធី ខ្លេម៉ិនស៍

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថាន អេសធី ខ្លេម៉ិនស៍ (ST CLEMENTS INSTITUTE) សរសេរកាត់ជាភាសាខ្មែរ "វ.អ.ខ" និងសរសេរកាត់ជាភាសាអង់គ្លេស "S.C.I" ។

**មាត្រា ២.-**

វិទ្យាស្ថាន អេសធី ខ្មែមិនស៍ មានទីតាំងស្ថិតនៅអគារលេខ១០២ ផ្លូវ៥៩៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣.-**

វិទ្យាស្ថាន អេសធី ខ្មែមិនស៍ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររង លើដេប៉ា-តឺម៉ង់ ចំនួន២ ដែលមានឯកទេសដូចខាងក្រោម ៖

១- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ច ៖

- ឯកទេសបដិសណ្ឋារកិច្ច និងទេសចរណ៍
- ឯកទេសគ្រប់គ្រងហិរញ្ញវត្ថុ និងធនាគារ
- ឯកទេសគ្រប់គ្រងពាណិជ្ជកម្ម

២- ដេប៉ាតឺម៉ង់បច្ចេកវិទ្យាព័ត៌មាន ៖

- ឯកទេសបច្ចេកវិទ្យាព័ត៌មាន

វិទ្យាស្ថាន អេសធី ខ្មែមិនស៍ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាល ។ ទៅអនាគត វិទ្យាស្ថាននេះអាចបើកសាខាដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មីឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤.-**

វិទ្យាស្ថាន អេសធី ខ្មែមិនស៍ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោល-នយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ ការរៀបចំក្រុមប្រឹក្សាភិបាល ត្រូវមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥.-**

នាយកវិទ្យាស្ថាន អេសធី ខ្មែមិនស៍ មានភារកិច្ច ៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន អេសធី ខ្មែមិនស៍ និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឲ្យចូលរៀន និងទទួលនិស្សិតឲ្យសិក្សាបន្ត តាមកម្មវិធីសិក្សារបស់វិទ្យាស្ថាន
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំ
- រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន និងវិធានផ្ទៃក្នុង សម្រាប់ការគ្រប់គ្រងការសិក្សាឲ្យបានច្បាស់លាស់
- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលមកក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។/.

**មាត្រា ៦.-**

និស្សិតវិទ្យាស្ថាន អេសធី ខ្លេមិនស៍ ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថាន អេសធី ខ្លេមិនស៍ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាន អេសធី ខ្លេមិនស៍ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមនាយកនៃវិទ្យាស្ថាន អេសធី ខ្លេមិនស៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១២

ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ